**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០ សសរ

# សេចក្តីសម្រេច
# ស្តីពីការកំណត់គោលការណ៍ធ្វើអាជីវកម្មខ្សាច់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១៩០៤ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការកែសម្រួលសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- បានឃើញលិខិតលេខ ០១៥ រថ. អធរ របា ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥ របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ ១៖** ប្រគល់ភារកិច្ចជូនក្រសួងរ៉ែ និងថាមពល ជាអ្នកចេញអាជ្ញាបណ្ណ និងទទួលខុសត្រូវគ្រប់បែបយ៉ាងលើការធ្វើអាជីវកម្មខ្សាច់គ្រប់ប្រភេទ ដោយគិតចាប់តាំងពីពេលដាក់ពាក្យស្នើសុំ រហូតដល់ការចេញអាជ្ញាបណ្ណ ។ រាល់អាជ្ញាបណ្ណ ដែលបានចេញទាំងអស់ ក្រសួងរ៉ែ និងថាមពល ត្រូវចម្លងជូនគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ជាកំហិត ។

**ប្រការ ២៖** មិនអនុញ្ញាតអោយចេញ « អាជ្ញាបណ្ណបណ្តោះអាសន្ន » ដាច់ខាត ។

**ប្រការ ៣៖** ក្នុងពេលអនុវត្តការធ្វើអាជីវកម្ម គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ក្រសួង ស្ថាប័នពាក់ព័ន្ធ មានសិទ្ធិធ្វើការតាមដាន ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ លើរាល់ចំណុចបច្ចេកទេស គោលការណ៍ លក្ខខណ្ឌ និងកាតព្វកិច្ច ដែលពាក់ព័ន្ធនឹងវិស័យរបស់ខ្លួន ជូនដល់ក្រសួងរ៉ែ និងថាមពល ដើម្បីធ្វើការកែលម្អជាបន្ទាន់ ។

**ប្រការ ៤៖** ក្នុងករណីមានភាពអនាធិបតេយ្យធ្ងន់ធ្ងរកើតឡើង ប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ត្រូវអញ្ជើញរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ( ឬតំណាងក្រសួងដែលមានសិទ្ធិសម្រេច ) ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសមាជិកគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ដើម្បីប្រជុំត្រួតពិនិត្យ វាយតម្លៃ និងសម្រេចវិធានការ ។

**ប្រការ ៥៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ ។